| ៥៨- លោកស្រី **សំ សោភ័ណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥៩- លោកស្រី **សុខ ចាន់រស្មី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦០- លោកស្រី **ហុង សុគន្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦១- លោក **គង់ ចំរើន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦២- លោកស្រី **អ៊ូង តារៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៣- លោកស្រី **អ៊ូច រដ្ឋនី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៤- លោកស្រី **ឈុន សុធារី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៥- លោក **រស់ មិថុនា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៦- លោកស្រី **ផន កែវផុន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៧- លោក **ឈឹម ហ៊ុយកែន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៨- លោកស្រី **រ័ត្ន ប៉ាណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៦៩- លោកស្រី **ណាន ម៉ៅ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧០- លោក **នើយ សុនាម** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧១- លោកស្រី **សឹង ផល្លី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧២- លោកស្រី **សុខ សម្ផស្ស** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៣- លោកស្រី **ម៉ូ ចំរើន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៧៤- លោកស្រី **គុណា សុមុនី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៥- លោកស្រី **ស៊ាន ចាន់ថន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៦- លោកស្រី **ឈុន ឆារិន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៧- លោកស្រី **ហ៊ី រចនា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៨- លោកស្រី **គិន មិច្ឆិកា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៧៩- លោកស្រី **ហោច សេរីវត្តី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨០- លោក **មុត សុគន់** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨១- លោកស្រី **អ៊ុត សុផានី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨២- លោកស្រី **នេត សុធារី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៣- លោកស្រី **យ៉េន កែវមន្ថា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៤- លោកស្រី **ម៉ម លក្ខិណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៥- លោកស្រី **បាន នារីរតនៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៦- លោកស្រី **យិន ស្រីឈូក** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៧- លោកស្រី **ហោច សីហា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៨- លោកស្រី **យិន ស៊ីដាពៅ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៨៩- លោកស្រី **ព្រិត សាយ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩០- លោកស្រី **ហាយ ស្រីមុំ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩១- លោកស្រី **ឈាន ចន្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩២- លោកស្រី **ថន គីមស្រ៊ន់** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៣- លោក **យ៉ាក់ រ៉ុន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៤- លោកស្រី **ភង ស៊ីម៉ែន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៥- លោកស្រី **យុន ចាន់ធុន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៦- លោកស្រី **ជ ចន្ធូ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៧- លោក **ម៉ម កេសី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៨- លោកស្រី **ឆែ មួយពៅ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៩៩- លោកជំទាវ **យ៉យ នីតា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០០- លោកស្រី **ខែអ ម៉ូនិលីន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០១- លោកស្រី **ប្រាក់ សោភា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០២- លោកស្រី **លន់ សុភា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០៣- លោកស្រី **ម៉ាត់ លីម៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០៤- លោកស្រី **ចាន់ ថ៉ានី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០៥- លោក **ហាច សុវណ្ណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០៦- លោក **ថ៉ាន់ ពៅ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០៧- លោក **អ៊ន់ បុត្រ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០៨- លោកស្រី **សៅ ផល្លា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

១០៩- លោកស្រី **លី សេខយ៉េត** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១០- លោកស្រី **ម៉ិច គីមឡៃន** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១១- លោកស្រី **ឆៀប សុផានី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១២- លោកស្រី **អុច ពុទ្ធារម្យ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១៣- លោកស្រី **សំ សោភា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១៤- លោក **សោម សាផន** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១៥- លោកស្រី **ម៉ាលី សុខនី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១៦- លោក **ឆួន សុធា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១៧- លោកស្រី **ប៉ែន ដារីកា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១៨- លោកស្រី **ឆួន ម៉ារី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុង មាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៥ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារ ដើម្បីចុះសិក្សា វាយតម្លៃ និងអភិវឌ្ឍគម្រោង របស់សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស ដែលមានទីតាំងនៅសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារដើម្បីចុះសិក្សា វាយតម្លៃ និងអភិវឌ្ឍគម្រោងរបស់សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** ដែលមានទីតាំងនៅសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ប្រធាន
- រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប អនុប្រធាន

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| - តំណាងក្រសួងធម្មការនិងសាសនា មួយចំនួន | សមាជិក។ |

សមាសភាពជាក់ស្តែងនៃក្រុមការងារនេះ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នសាមី។

**ប្រការ២.-**

ក្រុមការងារនេះ មានភារកិច្ចដូចតទៅ៖

- ចុះសិក្សា ស្រាវជ្រាវ និងវាយតម្លៃលើការគ្រប់គ្រងនិងការចុះបញ្ជីដីស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើដីដែលបានថ្វាយចំពោះសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** ដែលមានទីតាំងនៅសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប
- លើកសំណើជូនប្រមុខរាជរដ្ឋាភិបាលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការចាំបាច់នានា និងក្របខ័ណ្ឌសមិទ្ធកម្ម សម្រាប់អភិវឌ្ឍជាទីកន្លែងដើម្បីជាឧត្តមប្រយោជន៍ព្រះពុទ្ធសាសនា
- សម្របសម្រួលនិងផ្តល់ការគាំទ្រដល់ក្រុមជំនាញបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលសម្រេចបាននិងវឌ្ឍនភាពការងាររបស់ក្រុមការងារ ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យ សម្រេច និងផ្តល់អនុសាសន៍ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣.-**

ក្រុមការងារនេះ ត្រូវសហការជាមួយគណៈសង្ឃនាយកនៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជាដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ២នៃសេចក្តីសម្រេចនេះ។

**ប្រការ៤.-**

ក្រុមការងារនេះមានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយក្រសួងធម្មការនិងសាសនា និងមានទីតាំងនៅក្រសួងធម្មការនិងសាសនា។

សមាសភាពនិងរបៀបរបបការងារនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមការងារនេះ។

**ប្រការ៥ .-**

អនុប្រធាននិងសមាជិកនៃក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញពីប្រធាន។

ប្រធានក្រុមការងារនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមកិច្ចប្រជុំពិភាក្សាតាមការចាំបាច់។

អនុប្រធាននិងសមាជិកនៃក្រុមការងារនេះ ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារ។

ក្រុមការងារនេះ មានសិទ្ធិចាត់ចែងមន្ត្រីក្រោមឱវាទ ដើម្បីជួយបំពេញការងារតាមការចាំបាច់។

ក្រុមការងារនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងធម្មការនិងសាសនា។

**ប្រការ៦ .-**

ថវិកាចំណាយ មធ្យោបាយ និងសម្ភារបរិក្ខារសម្រាប់បំពេញបេសកកម្មការងាររបស់ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារនេះ ជាបន្ទុករបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០១ សណន

## សេចក្តីណែនាំ
## ស្តីពី
## ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានកំណត់ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ គឺការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជនឱ្យកាន់តែប្រសើរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលក្នុងនោះរួមមាន ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ នៅក្នុងកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា (**គ.វ.រ**) កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិបានណែនាំដល់ក្រសួង ស្ថាប័នឱ្យធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីធានាការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នមានប្រសិទ្ធភាពខ្ពស់។

ជាការកត់សម្គាល់ ក្រសួង ស្ថាប័នមួយចំនួនបាននិងកំពុងធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ដែលឈានដល់ការកាត់បន្ថយ ការកែសម្រួល ការច្របាច់បញ្ចូលគ្នា ឬការលុបចោលមុខងារ និងអង្គភាពមួយចំនួនក្រោមឱវាទរបស់ខ្លួន។ ដើម្បីជំរុញបន្ថែមដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងការធានាបាននូវសង្គតិភាពនៃដំណើរការនេះ រាជរដ្ឋាភិបាលសូមណែនាំដល់ក្រសួង ស្ថាប័នក្នុងក្របខណ្ឌនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន ដូចខាងក្រោម៖

### ១. គោលបំណង

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័នមានគោលបំណងលើកកម្ពស់ដំណើរការនៃក្រសួង ស្ថាប័នឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ក្នុងក្របខណ្ឌនៃការបំពេញមុខងារនិងបេសកកម្មរបស់ខ្លួន ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បី៖

- ផែនាបានថាមុខងាររបស់ក្រសួង ស្ថាប័នត្រូវបានអនុវត្តដោយត្រឹមត្រូវនិងសមស្របគាំទ្រដល់ការសម្រេចគោលបំណងនៃបេសកកម្មរបស់ក្រសួង ស្ថាប័ន
- វាយតម្លៃសមត្ថភាពគន្លឹះដែលចាំបាច់របស់ក្រសួង ស្ថាប័ន និងវិសាលភាពនៃការងារដែលត្រូវអនុវត្តដើម្បីគាំទ្រការលើកកម្ពស់សមត្ថភាពនេះ
- ពិនិត្យឡើងវិញតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងដែនកំណត់នៃសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- វាយតម្លៃប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃសកម្មភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលបានឬនឹងត្រូវបំពេញ
- ពិនិត្យឡើងវិញជម្រើសទាំងឡាយនៃការផ្តល់សេវា និងធានាថាសកម្មភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលត្រូវអនុវត្តមានលក្ខណៈសមស្របជាមួយជម្រើសនោះ
- ធានាថាសកម្មភាពនិងធនធានរបស់ក្រសួង ស្ថាប័ន ដែលត្រូវប្រើប្រាស់ឆ្លើយតបនឹងគោលបំណងនៃសេវា និងអ្នកប្រើប្រាស់សេវា។

## ២. ភាពចាំបាច់នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន គឺដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមមួយចំនួនដែលក្រសួង ស្ថាប័នបាននិងកំពុងជួបប្រទះ រួមមាន៖

- ភាពមិនច្បាស់លាស់ឬការត្រួតជាន់គ្នានៃមុខងារ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- ភាពខ្វះចន្លោះនៃការធ្វើអាទិភាវូបនីយកម្ម និងការផ្តោតលើសកម្មភាពដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់ ឈរលើមូលដ្ឋាននៃធនធានថវិកានិងមនុស្សរបស់ក្រសួង ស្ថាប័ន
- ភាពស្មុគស្មាញនិងបញ្ហាលំបាកនៅក្នុងអន្តរទំនាក់ទំនងរវាងក្រសួង ស្ថាប័ន និងក្រសួង ស្ថាប័ន ឬរវាងអង្គភាពនិងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នតែមួយ
- បញ្ហាអសង្គតិភាពឬភាពមិនរលូននិងប្រទាក់ក្រឡានៃការកំណត់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល វិស័យ ឬរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- បណ្តឹងតវ៉ាឬការមិនពេញចិត្តពីភាគីពាក់ព័ន្ធឬអ្នកប្រើប្រាស់សេវា ចំពោះកម្រិតគុណភាពនៃសេវាដែលផ្តល់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- ផលប៉ះពាល់នៃការប្រើប្រាស់បច្ចេកវិទ្យាថ្មី ក្នុងការអនុវត្តមុខងារ និងសកម្មភាពការងារទាំងឡាយរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។

## ៣. គោលដៅនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ប្រឈមនឹងបញ្ហាខាងលើ ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធមានគោលដៅចម្បងគឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការចំណាយថវិកា ការប្រើប្រាស់ធនធានមនុស្សនិងការងាររាជរដ្ឋាភិបាល នៅក្នុងការអនុវត្តមុខងារនិងបេសកកម្មរបស់ក្រសួង ស្ថាប័ន។ លទ្ធផលនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធនឹងអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អាចកំណត់បាននូវ៖

- មុខងារនិងរចនាសម្ព័ន្ធថ្មី ដែលសមស្របនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងរបស់វិស័យនីមួយៗ
- ការចាត់ចែងប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ក្នុងការអនុវត្តមុខងារ
- ការគ្រប់គ្រងនិងចាត់ចែងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដោយកំណត់បានពិតប្រាកដនូវតម្រូវការធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពមន្ត្រី និងការពង្រាយមន្ត្រី
- សមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ដែលមានភាពច្បាស់លាស់ អាចត្រួតពិនិត្យនិងវាយតម្លៃបាន ព្រមទាំងមានភាពកាន់តែប្រសើរ។

## ៤. គោលការណ៍ទូទៅ

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធត្រូវអនុវត្តដោយក្រសួង ស្ថាប័នសាមីនិងត្រូវផ្អែកលើគោលការណ៍ទូទៅ ដូចខាងក្រោម៖

- ការធានានូវការសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៧ នៃរដ្ឋសភា
- ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ផ្អែកលើអភិក្រមជាភាពនៃប្រព័ន្ធតួអង្គតែមួយ
- ភាពជាម្ចាស់ ស្មារតីទទួលខុសត្រូវ និងនវានុវត្តន៍របស់ក្រសួង ស្ថាប័ន
- ប្រសិទ្ធភាពខ្ពស់នៃដំណើរការរដ្ឋបាលសាធារណៈ ដោយមានការកំណត់មុខងារនិងរចនាសម្ព័ន្ធ ការប្រើប្រាស់ធនធានមនុស្ស ថវិកា និងបច្ចេកវិទ្យាសមស្របនិងចំគោលដៅ ដើម្បីសម្រេចបានសមិទ្ធកម្មកាន់តែប្រសើរ សម្រាប់ប្រជាជន
- ការរក្សាប្រយោជន៍មន្ត្រីពាក់ព័ន្ធនឹងអង្គវិជ្ជាជីវៈ ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ បៀវត្ស និងប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងករណីមានការកែសម្រួលមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន។

## ៥. វិសាលភាពនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ត្រូវរៀបចំនិងអនុវត្តសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ។

## ៦. ក្របខណ្ឌពេលវេលាអនុវត្ត

ក្រសួង ស្ថាប័នត្រូវធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័នជាលក្ខណៈរួមឱ្យបានរួចរាល់ ក្នុងឆមាសទី១ នៃឆ្នាំ២០២៤ ដោយកំណត់ឱ្យបានច្បាស់លាស់នូវមុខងារនិងរចនាសម្ព័ន្ធ ព្រមទាំងតម្រូវការសមស្របនៃការប្រើប្រាស់ធនធានមនុស្សនិងថវិកា ដែលធានាថាមុខងារនិងបេសកកម្មរបស់ក្រសួង ស្ថាប័ននឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ នៅដំណាក់កាលបន្ទាប់ ក្រសួង ស្ថាប័នត្រូវបន្តការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័នដោយផ្តោតលើមុខងារស្នូលដែលជាមុខងារមានលក្ខណៈគាំទ្រទូទៅរបស់អង្គភាពនៃក្រសួង ស្ថាប័ន និងមុខងារជំនាញរបស់អង្គភាពនៃក្រសួង ស្ថាប័ន ផ្អែកលើការណែនាំដោយឡែករបស់គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

## ៧. វិធីសាស្ត្រអនុវត្ត

ក្រសួង ស្ថាប័ន ត្រូវធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ដោយគិតគូរឈរលើមូលដ្ឋានដូចខាងក្រោម៖

### ៧.១ ការណែនាំសម្រាប់ការពិនិត្យឡើងវិញនិងការវិភាគមុខងារ

- ការផ្សារភ្ជាប់មុខងាររបស់ក្រសួង ស្ថាប័ន ជាមួយគោលបំណងជាយុទ្ធសាស្ត្រនិងការងារអាទិភាពជាយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាលជារួម។ ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវទីតាំងរបស់ខ្លួនក្នុងការអនុវត្តមុខងារនិងបេសកកម្ម ការផ្សារភ្ជាប់សកម្មភាពដើម្បីគាំទ្រការងារអាទិភាពជាយុទ្ធសាស្ត្រ ការស្វែងយល់អំពីនិន្នាការខាងក្រៅបញ្ហាខាងក្នុង និងការងារអាទិភាពជាយុទ្ធសាស្ត្រ
- ការពិនិត្យឡើងវិញនូវសេចក្តីត្រូវការនិងការរំពឹងទុករបស់ភាគីពាក់ព័ន្ធ ពិសេសអ្នកប្រើប្រាស់សេវា និងនិយាមសេវាផ្តល់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន
- ការពិនិត្យ ការស្វែងយល់ និងការប្រៀបធៀបជាមួយឧត្តមានុវត្តន៍ក្នុងការផ្តល់សេវាសាធារណៈដោយត្រូវគិតគូរដល់ជម្រើសទាំងឡាយ ពាក់ព័ន្ធនឹងអភិក្រមនៃការផ្តល់សេវាប្រកបដោយឧត្តមភាព
- ការវាយតម្លៃសមត្ថភាពបច្ចុប្បន្ន និងអនាគតរបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទដែលចាំបាច់ក្នុងក្របខណ្ឌនៃការអនុវត្តការងារ អភិក្រមនៃការផ្តល់សេវា ការបំពេញសមត្ថកិច្ចការប្រើប្រាស់ឧបករណ៍ មធ្យោបាយផ្សេងៗ និងប្រព័ន្ធដំណើរការ
- ការស្វែងរកមតិយោបល់ និងការពិភាក្សាជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកំណត់នូវភាពប្រឈម ជម្រើសជាដំណោះស្រាយ និងកាលានុវត្តភាពនៃការកែលម្អដំណើរការការងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ។

### ៧.២ ក្របខណ្ឌគោលនយោបាយនិងគតិយុត្ត

ក្រសួង ស្ថាប័នត្រូវធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ដោយផ្អែកលើ៖

- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាមូលដ្ឋានគោល
- គោលនយោបាយតាមវិស័យដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល
- ផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមនិងវែងរបស់ក្រសួង ស្ថាប័ន
- ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

### ៧.៣ ក្របខណ្ឌថវិកានិងធនធានមនុស្ស

ការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ ត្រូវអនុវត្តផ្អែកលើគោលការណ៍នៃការធានានូវប្រសិទ្ធភាព ដូចខាងក្រោម៖

- ការគ្រប់គ្រងចំណាយលើបន្ទុកបុគ្គលិក ដោយត្រូវរក្សាក្នុងកម្រិតមិនឱ្យលើសពិដានចំណាយបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័ន ដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសេចក្តីណែនាំស្តីពីហិរញ្ញវត្ថុសាធារណៈ
- ការប្រើប្រាស់ធនធានមនុស្សឱ្យចំជំនាញ ដោយមានការបែងចែកភារកិច្ចច្បាស់លាស់មានប្រព័ន្ធគ្រប់គ្រងវត្តមាន និងសមិទ្ធកម្មការងារ។

## ៧.៤ នីតិវិធីនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នត្រូវពិនិត្យឡើងវិញមុខងាររបស់ខ្លួន ដោយធៀបជាមួយនឹងមុខងាររបស់ក្រសួង ស្ថាប័នដទៃទៀតក្នុងក្របខណ្ឌរាជរដ្ឋាភិបាលនិងវិស័យ និងការពិនិត្យឡើងវិញរចនាសម្ព័ន្ធនិងមុខងារអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នផងដែរ។ ផ្អែកលើក្របខណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធ ក្រសួង ស្ថាប័នត្រូវកំណត់និងរៀបចំបញ្ជីមុខងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទរបស់ខ្លួន ដែលមុខងារទាំងនោះ អាចត្រូវធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

**ប្រភេទ ១៖** មុខងារចាត់ទុកថាជាមុខងាររបស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលកំពុងអនុវត្តជាក់ស្តែង៖

ក. មានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត

ខ. មានកំណត់ក្នុងគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ តែមិនមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត

គ. មិនមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត ឬក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន

**ប្រភេទ២៖** មុខងារចាត់ទុកថាជាមុខងាររបស់ក្រសួង ស្ថាប័ននិងអង្គភាពក្រោមឱវាទ ប៉ុន្តែមិនបានអនុវត្តជាក់ស្តែង

ក. មានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត ឬកំណត់ក្នុងក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន

ខ. មិនទាន់មានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័ន ក្រោយពីបានរៀបចំបញ្ជីមុខងាររបស់ខ្លួន ត្រូវធ្វើការវិភាគ ដោយបែងចែកមុខងារជាបួនប្រភេទគឺ៖

ក. **មុខងារគួររក្សាទុក៖** ជាមុខងារច្បាស់លាស់ក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអង្គភាព

ខ. **មុខងារគួរមានការកែលម្អឡើងវិញ៖** ជាមុខងារដែលត្រូវមានការពិនិត្យ ពិភាក្សា និងសម្រេចជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដោយហេតុមានលក្ខណៈត្រួតគ្នា មិនច្បាស់លាស់ក្នុងដែនសមត្ថកិច្ចអនុវត្ត ត្រូវបានធ្វើប្រតិភូកម្មឬផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

គ. **មុខងារគួរលុបចោល៖** ជាមុខងារដែលមិនសូវសំខាន់ មិនសូវផ្តល់ប្រយោជន៍សាធារណៈ មានតម្លៃបន្ថែមទាប មានតម្រូវការតិចតួច គ្មានតម្រូវការពីអ្នកទទួលសេវា ត្រូវបានធ្វើប្រតិភូកម្មឬផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ឃ. **មុខងារគួរផ្ទេរចេញ៖** ជាមុខងារគួរផ្ទេរទៅក្រសួង ស្ថាប័នផ្សេង ឬគួរធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិ ដោយហេតុត្រួតជាន់គ្នាជាមួយក្រសួង ស្ថាប័នផ្សេង ដែលក្រសួង ស្ថាប័នផ្សេងអាចអនុវត្តដោយប្រសិទ្ធភាពជាង ឬគួរធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិព្រោះជាមុខងារផ្តល់សេវាសាធារណៈដែលនៅកៀកនឹងប្រជាពលរដ្ឋ។

### ៧.៥ ការពិគ្រោះយោបល់

ក្រសួង ស្ថាប័ន ត្រូវពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ នៅក្នុងដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ។

### ៧.៦ ការកែសម្រួលមុខងារនិងរចនាសម្ព័ន្ធ

ក្រោយពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរួចរាល់ ក្រសួង ស្ថាប័នត្រូវកំណត់និងសម្រេចលើការរក្សាទុកដដែល ការកែលម្អ ឬការរៀបចំរចនាសម្ព័ន្ធឡើងវិញឱ្យស្របនឹងមុខងារដែលក្រសួង ស្ថាប័នត្រូវទទួលបន្ទុក។ លើសពីនេះ ក្រសួង ស្ថាប័នត្រូវយកចិត្តទុកដាក់ក្នុងការបង្រួមបញ្ចូលគ្នា ឬលុបចោលរចនាសម្ព័ន្ធដែលមិនចាំបាច់ និងគួររៀបចំរចនាសម្ព័ន្ធថ្មីដែលមានទំហំសមស្រប។

### ៧.៧ ការរៀបចំនិងការប្រើប្រាស់ធនធានមនុស្សនិងថវិកាគាំទ្រមុខងារ

ក្រសួង ស្ថាប័នត្រូវរៀបចំនិងចាត់ចែងការប្រើប្រាស់ធនធានមនុស្សនិងថវិកាឱ្យបានត្រឹមត្រូវ និងសមស្របក្នុងក្របខណ្ឌនៃការអនុវត្តមុខងារតាមរចនាសម្ព័ន្ធនីមួយៗ ព្រមទាំងរៀបចំប្រព័ន្ធការងារឱ្យបានច្បាស់លាស់ ដើម្បីធានាថាធនធានមនុស្សនិងថវិកាដែលមានត្រូវបានចាត់ចែងនិងប្រើប្រាស់អស់លទ្ធភាពនិងសក្តានុពល ដើម្បីសម្រេចចក្ខុវិស័យ បេសកកម្ម និងមុខងាររបស់ក្រសួង ស្ថាប័ន។

### ៧.៨ នីតិវិធីបន្ទាប់ពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ

ក្រោយពីធ្វើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរួច ក្រសួង ស្ថាប័នត្រូវរៀបចំឯកសារជូនមកក្រសួងមុខងារសាធារណៈ ដែលជាលេខាធិការដ្ឋាននៃ គ.វ.រ ដើម្បីបូកសរុបនិងរាយការណ៍ជូនគណៈកម្មាធិការជាតិ (ផ្អែកលើតារាងគំរូមានក្នុងឧបសម្ព័ន្ធ) ដែលរួមមាន៖

- របាយការណ៍នៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធ
- តម្រូវការធនធានមនុស្សរបស់ក្រសួង ស្ថាប័ន ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨
- តម្រូវការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់ក្រសួង ស្ថាប័ន ឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨
- ផែនការពង្រាយមន្ត្រីរាជការក្នុង និងក្រៅក្រសួង ស្ថាប័ន។

## ៨. យន្តការស្ថាប័នដឹកនាំនិងអនុវត្ត

### ៨.១ គណៈកម្មការដឹកនាំការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

គណៈកម្មការដឹកនាំការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន នឹងត្រូវបង្កើតឡើងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញតួនាទីជួយដល់ គ.វ.រ. លើការងារដឹកនាំ សម្របសម្រួល គ្រប់គ្រង និងតម្រង់ទិសការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។

### ៨.២ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកដឹកនាំនិងសម្របសម្រួលការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័ន អាចបង្កើតក្រុមការងារបច្ចេកទេសមួយឬច្រើនតាមការចាំបាច់ ដើម្បីសម្របសម្រួលនិងគាំទ្រដំណើរការនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។

## ៩. យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្រសួងមុខងារសាធារណៈ ក្នុងនាមជាលេខាធិការដ្ឋាននៃគ.វ.រ ត្រូវចាត់ចែងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ដើម្បីធានាការអនុវត្ត ការគាំទ្រ ការតាមដានការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសេចក្តីណែនាំនេះ។ ទន្ទឹមនេះ ក្រសួងមុខងារសាធារណៈត្រូវរាយការណ៍ជាប្រចាំជូនគ.វ.រ. អំពីវឌ្ឍនភាព បញ្ហាប្រឈមនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងស្នើជម្រើសវិធានការសមស្រប ដើម្បីគាំទ្រនិងជំរុញកិច្ចការនេះឱ្យអនុវត្តដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភាត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១៤ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៨៦ ឧវបន. គក. ប្រកា

ថ្ងៃ...... ខែ...... ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៣៩៤៣/១៨ គ.វ.ក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតរោងចក្រផលិតកាបូប និងខ្សែក្រវ៉ាត់គ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ របស់ក្រុមហ៊ុន ហបឡុក (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ហបឡុក (ខេមបូឌា) ឯ.ក** (HOPLOK (CAMBODIA) CO., LTD.) តំណាងដោយលោក **YANG, HONGCEN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EE8810582** ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ បង្កើតរោងចក្រ**ផលិតកាបូប និងខ្សែក្រវ៉ាត់គ្រប់ប្រភេទ** ដែលមានទីតាំងស្ថិតនៅ**ភូមិត្រពាំងប្រុយ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។**

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- កាបូប | ១៥១២ |
| ២- ខ្សែក្រវាត់គ្រប់ប្រភេទ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រផលិតកាបូប និងខ្សែក្រវាត់គ្រប់ប្រភេទ ហបឡុក (ខេមបូឌា) ឯ.ក"**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០៣១ ឧស.កឧ.ប្រក.០១ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ហេង សុខគង់

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកណ្តាល
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល
- -រដ្ឋបាលស្រុកអង្គស្នួល
- -រដ្ឋបាលឃុំបែកចាន

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation
លេខ: ០៩៤ [illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់លេខ១០៣២/០៦ គ.អ.ក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រុមហ៊ុន អេវើគ្រីន ហ្គាមេន ខូ អេលធីឌី

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **អេវើគ្រីន ហ្គាមេន ខូ អេលធីឌី (EVERGREEN GARMENT CO., LTD.)** តំណាងដោយលោក **SHIN DONG HYUK** សញ្ជាតិកូរ៉េ កាន់លិខិតឆ្លងដែនលេខ **M26753843** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៨ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅ**ដីឡូត៍លេខ២៨៩ ផ្លូវជាតិលេខ៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។**

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រកាត់ដេរសម្លៀកបំពាក់ អេវើរគ្រីន ហ្វាមេន ខូ អេលធីឌី "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០៨៣ ឧវបន.កឧ.ប្រក.០២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ និងលិខិតលេខ ២៣០៨ ឧវបន.កឧ.លស ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ ស្តីពីការប្តូរប្រធានក្រុមប្រឹក្សាភិបាល របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌឬស្សីកែវ
-រដ្ឋបាលសង្កាត់ឫស្សីកែវ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ០៩៣...ឧវបន...ចក...ប្រក

ថ្ងៃ សុក្រ ១០ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២៤

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ០៥៥/២៤ គ.វ.ក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ម៉េជិក អ៊ីភែរ៉ឺល អ៊ិនដាសស្ទ្រៀល ឯ.ក

## ស ម្រេ ច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ម៉េជិក អ៊ីភែរ៉ឺល អ៊ិនដាសស្ទ្រៀល ឯ.ក** (**MAGIC APPAREL INDUSTRIAL CO., LTD.**) តំណាងដោយលោក **LU, XIAOJIANG** សញ្ញាតិចិន កាន់លិខិតឆ្លងដែនលេខ **EH1186106** ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅ**ភូមិតាំងក្រសាំង ឃុំញាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ**។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ មែដឹក អីកែរីល អ៊ិនដាសស្ទ្រៀល ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

